**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**មន្ទីរកសិកម្មខេត្តកំពង់ធំ**

# របាយការណ៍ស្តីពី
# ការរីកចម្រើនលើការងារផលិតកម្ម អាជីវកម្មកសិកម្មប្រចាំខែកក្កដា
គិតចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦

## I-ស្ថានភាពទូទៅ
កំពង់ធំជាខេត្តមួយស្ថិតនៅចំកណ្តាល នៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ១៦៨គ.មពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន១៥.០៦១គ.ម² ស្មើនឹង១.៥០៦.១៩៧ហ.ត មានក្រុងចំនួន ០១ ស្រុកចំនួន ០៧ សង្កាត់ចំនួន ០៨ ឃុំចំនួន ៧៣ ភូមិចំនួន ៧៣៧ ។ មានប្រជាពលរដ្ឋសរុបចំនួន ៧៤៣.៥៩៩នាក់ ស្រីចំនួន ៣៧៨.១៩៥នាក់ ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើងមានចំនួន ៤១៩.១៧៤ នាក់ ស្រីចំនួន ២១៨.១៧៤នាក់ មាន១៤៦.៦០៤គ្រួសារ ។ ដង់ស៊ីតេប្រជាពលរដ្ឋ ៤៨នាក់ ក្នុង១គីឡូម៉ែត្រក្រឡា មានប្រជាពលរដ្ឋ ៧៥ - ៨០ ភាគរយប្រកបរបរកសិកម្ម ។

មានស្ទឹងសំខាន់ៗចំនួន ០៤គឺៈ ស្ទឹងសែន ស្ទឹងជីនិត ស្ទឹងស្ទោង និងស្ទឹងតាំងក្រសាំង ទឹកស្ទឹងទាំងនេះហូរចូលបឹងទន្លេសាប ។

### ក-ស្ថានភាពភូមិសាស្ត្រចែកចេញជា ០២តំបន់សំខាន់ៗគឺៈ
១).តំបន់ខ្ពង់រាបៈ ស្ថិតនៅផ្នែកខាងលើផ្លូវជាតិលេខ ០៦ ជាតំបន់ខ្ពង់រាបដែលអាចដាំដុះដំណាំកសិឧស្សាហកម្ម ដំណាំរួមផ្សំ កៅស៊ូ និងដំណាំឈើហូបផ្លែ ពិសេសនៅស្រុកសណ្តាន់ ភាគច្រើនជាតំបន់ដីក្រហម ដែលជាដីមានជីជាតិល្អជាងតំបន់នានាក្នុងខេត្ត

២).តំបន់វាលទំនាបៈ ស្ថិតនៅផ្នែកខាងក្រោមផ្លូវជាតិលេខ០៦ ជាតំបន់វាលរាបលាតសន្ធឹងដល់មាត់បឹងទន្លេសាប មានព្រៃលិចទឹក បឹងបួរត្រពាំង និងមានផ្ទៃដីសម្រាប់ដំណាំស្រូវឡើងទឹក ។ បច្ចុប្បន្នពិពិធកម្មកសិកម្មបានប្រែក្លាយបែបផែនផលិតកម្មពីការធ្វើស្រូវឡើងទឹក មកធ្វើស្រូវដើមរដូវ និងស្រូវប្រាំងដោយសាងសង់អាងស្តុកទឹកទុកសម្រាប់ស្រោចស្រព ។

### ខ-ស្ថានភាពឧតុនិយម និងជលសាស្ត្រ
- គិតត្រឹមថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ទឹកភ្លៀងមានកម្ពស់ ៥៧៤,៨ម.ម ធៀបនឹងឆ្នាំ ២០១៥ ខ្ពស់ជាង ៨២,៥ម.ម
- គិតត្រឹមថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៦ ទឹកស្ទឹងសែនមានកម្ពស់ ១២.៣០ម ធៀបនឹងឆ្នាំ ២០១៥ ខ្ពស់ជាង ០,៤៤ម ។

## II-ការងារសហប្រតិបត្តិការ
មន្ទីរកសិកម្មខេត្តកំពង់ធំ បានកំពុងអនុវត្តគម្រោង និងសកម្មភាពនានា ដោយសហការជាមួយអង្គការជាដៃគូដូចខាងក្រោមៈ

### ក-គម្រោងដែលកំពុងអនុវត្ត
- គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប (Tonle Sap Poverty Reduction and Small Holder Development Project) "TSPRSDP"
- គម្រោងកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice-SDP)

- គម្រោងលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀង (Improvement of Livelihoods and Food Security Project, ILF របស់គម្រោង GIZ)

**ខ-សហការជាមួយដៃគូ**

- អង្គការទស្សនពិភពលោក (World Vision) ក្នុងការផ្តល់សេវាបច្ចេកទេសដាំដុះដំណាំស្រូវ, ដំណាំបន្លែ, ការចិញ្ចឹមសត្វ, និងការបញ្ជ្រាបកម្មវិធីអភិវឌ្ឍន៍នានា
- អង្គការអ៊ុកហ្វាម (Oxfam) ក្នុងការផ្តល់សេវាបច្ចេកទេសដាំដុះដំណាំស្រូវដំណាំបន្លែ និងការចិញ្ចឹមសត្វ
- គម្រោង ជួយដោះស្រាយភាពងាយរងគ្រោះនៅជនបទ និងស្ថេរភាពប្រព័ន្ធអេកូឡូស៊ី (កម្ពុជាហាវែស/Cambodia HARVEST)
- អង្គការគ្រីះសាសនាបម្រើពិភពលោក Church World Service (CWS Cambodia)
- អង្គការស្រែខ្មែរ
- សកម្មភាពដើម្បីអភិវឌ្ឍន៍ (Action For Development ហៅកាត់ថា AFD)
- អង្គការសង្គ្រោះជនទុរគត និងមនុស្សចាស់ (HOM)
- អង្គការស្បៀងអាហារ និងកសិកម្ម នៃអង្គការសហប្រជាជាតិ (Food and Agriculture of United Nation ហៅកាត់ថា FAO)
- មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC)

## III-លទ្ធផលសម្រេចបានលើការងារផលិតកម្មកសិកម្ម

### ១-ការងាររដ្ឋបាល បុគ្គលិក

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីរាជការសរុបចំនួន ១៧នាក់ ស្រីចំនួន ០៦នាក់ ក្នុងនោះមន្ត្រីជាប់កិច្ចសន្យាចំនួន ០៣នាក់ ស្រីចំនួន ០២នាក់ ។ ការិយាល័យនេះដឹកនាំដោយប្រធាន ០១រូប ។

**១.១-ការងាររដ្ឋបាល**

គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ មន្ទីរទទួលបានលិខិតចូលចំនួន **២៣៨ច្បាប់** និងចេញលិខិតចំនួន **១៩៤ច្បាប់** ព្រមទាំងចាត់ចែងការងារប្រចាំថ្ងៃយ៉ាងមមាញឹកតាមការចង្អុលបង្ហាញពីថ្នាក់ដឹកនាំមន្ទីរ ។

**១.២-ការងារបុគ្គលិក/មន្ត្រីរាជការ**

មន្ទីរកសិកម្មខេត្តកំពង់ធំ ដឹកនាំដោយប្រធានមន្ទីរ ០១រូប អមដោយអនុប្រធានមន្ទីរចំនួន ០២រូប ។ គិតត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៦ មន្ទីរកសិកម្មខេត្តកំពង់ធំមានក្របខណ្ឌមន្ត្រីរាជការសរុបទាំងអស់ចំនួន ១៣៦នាក់ ស្ត្រី ៣៧នាក់ក្នុងនោះមន្ត្រីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០៧នាក់ និងមន្ត្រីកម្មសិក្សាឆ្នាំ២០១៦ មានចំនួន ០៦នាក់ ស្រីចំនួន ០២នាក់ ។ មន្ត្រីជាប់កិច្ចសន្យាសរុបចំនួន ១០នាក់ ស្រីចំនួន ០៦នាក់ ។

មន្ទីរកសិកម្មបានរៀបចំកិច្ចប្រជុំប្រចាំខែ នូវរៀងរាល់ពាក់កណ្តាល នៃខែនីមួយៗតាមកម្មវិធីប្រចាំខែ/ឆ្នាំ ដើម្បីពង្រឹងការអនុវត្តការងាររបស់មន្ត្រីរាជការ និងបូកសរុបលទ្ធផលការងារដែលបានអនុវត្តតាមបណ្តាក្រុង ស្រុកគ្រប់ស្រុក និងតាមផ្នែកជំនាញរបស់ការិយាល័យជុំវិញមន្ទីរ ក្នុងគោលបំណងសិក្សាផលប៉ះពាល់ជាអវិជ្ជមាន ដើម្បីមានមូលដ្ឋានលើកទិសដៅ សម្រាប់អនុវត្តបន្ត ។

### ១.៣-សកម្មភាពការងារ

សកម្មភាពការងារដែលការិយាល័យរដ្ឋបាល បុគ្គលិកបានចូលរួមៈ

- បូកសរុបរបាយការណ៍របស់មន្ទីរកសិកម្ម
- ទទួលបញ្ជីវត្តមានតាមបណ្តាការិយាល័យ ដើម្បីបូកសរុបថតចម្លងផ្ញើជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ត្រួតពិនិត្យការធ្វើអនាម័យប្រចាំថ្ងៃ និងការធ្វើពលកម្មរៀងរាល់ថ្ងៃសុក្រ នៃសប្តាហ៍
- រៀបចំសាលប្រជុំសម្រាប់កិច្ចប្រជុំផ្សេងៗ
- ការស្រាវជ្រាវ និងការរៀបចំទុកដាក់ឯកសារ "Clear"
- សម្របសម្រួលដោះស្រាយការងារមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែត
- ត្រួតពិនិត្យបញ្ជីវត្តមានប្រចាំខែ និងរៀបឯកសារសម្រាប់ការធ្វើរបាយការណ៍ផ្សេងៗទៀត
- ចាត់ចែងការងារប្រចាំថ្ងៃ
- រៀបចំឯកសារស្នើសុំមេដាយសម្រាប់ឆ្នាំ២០១៥ និងពិភាក្សាដោះស្រាយកិច្ចការតាមបណ្តាឆ្នាំកន្លង
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ពិធីប្រកាសផ្ទេរភារកិច្ច, តែងតាំង និងប្រគល់ភារកិច្ចជូនប្រធានការិយាល័យចំណុះមន្ទីរកសិកម្ម និងការិយាល័យកសិកម្មក្រុង ស្រុកចំនួន ១២រូប
- ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៦ ប្រារព្ធពិធីអបអរសាទរ ទិវានារីអន្តរជាតិ នៅមន្ទីរកសិកម្មខេត្តកំពង់ធំ
- ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំផ្សព្វផ្សាយលិខិតលេខ ៤៨៧ មស.ក្រខ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីផែនការជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងឧទ្យានុរក្ស របស់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងមន្ទីរ អង្គភាពជំនាញរាជធានី ខេត្តសម្រាប់ឆ្នាំ២០១៦ នៅមន្ទីរមុខងារសាធារណៈខេត្តកំពង់ធំ

## ២-ការខារផែនការ គណនេយ្យ

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីសរុបចំនួន ១៦នាក់ ស្រីចំនួន ០៣នាក់, ក្នុងនោះមន្ត្រីជាប់កិច្ចសន្យាចំនួន ០២នាក់ ស្រីចំនួន ០១នាក់ ។ ការិយាល័យនេះដឹកនាំដោយប្រធាន ០១រូប ។

ជារួមការងារស្ថិតិកសិកម្មត្រូវបានពង្រឹង និងរីកចម្រើនជាបន្តបន្ទាប់ ខាងសមត្ថភាពធនធានមនុស្សវិធីសាស្ត្រការងារអង្កេតដូចជាយន្តការ នៃការដឹកនាំគ្រប់គ្រងប្រមូល និងចែកចាយ នៃទិន្នន័យស្ថិតិកសិកម្មមានលទ្ធផលដូចខាងក្រោមៈ

- ប្រមូលរបាយការណ៍តាមបណ្តាស្រុក ក្រុងទូទាំងខេត្តដែលពាក់ព័ន្ធនឹងការងារស្ថិតិ
- ពិនិត្យតាមដានការងារបង្កបង្កើនផលដំណាំស្រូវដំណាំរួមផ្សំ និងដំណាំកសិឧស្សាហកម្ម
- ពិនិត្យ និងតាមស្ថានភាពធាតុអាកាសនៅតាមបណ្តាស្រុក ក្រុង ដើម្បីជំរុញអោយប្រព័ន្ធការងារស្ថិតិមានភាពសុក្រិត្យ និងមានភាពជឿជាក់លើទិន្នន័យ ដែលប្រមូលបានពីតាមបណ្តាស្រុក ក្រុងដោយមានការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងយុទ្ធសាស្ត្រកំណែទម្រង់វិស័យរដ្ឋបាលសាធារណៈ, វិស័យហិរញ្ញវត្ថុសាធារណៈ និងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បង្កើតបណ្តាញប្រព័ន្ធទូរស័ព្ទ សម្រាប់ឲ្យប្រជាពលរដ្ឋទូទាំងខេត្តងាយស្រួលទំនាក់ទំនងចង់ដឹងពីផ្នែកទីផ្សារកសិកម្ម ។

**២.១-គម្រោងកាត់បន្ថយភាពក្រីក្រជុំវិញបឹងទន្លេសាប (TSSD)**

- ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ពិនិត្យការអនុវត្តន៍សកម្មភាពគម្រោងនៅស្រុកបារាយណ៍
- ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ពិនិត្យការអនុវត្តន៍កសិកម្មល្អ (GAP) នៅស្រុកសន្ទុក
- ថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០១៦ វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញស្តីពីការគ្រប់គ្រងសៀវភៅប្រតិបត្តិរបស់ក្រុមកសិករផលិតស្រូវពូជ អ្នកចូលរួមសរុបចំនួន ៣៨នាក់ ស្រីចំនួន ០៨នាក់
- ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៦ ពិនិត្យការអនុវត្តន៍សកម្មភាពគម្រោង នៅស្រុកស្ទោង
- ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ពិនិត្យការអនុវត្តន៍កសិកម្មល្អ (GAP) លើដំណាំត្រសក់នៅស្រុកសណ្តាន់
- ថ្ងៃទី១៤-១៥ ខែកក្កដា ឆ្នាំ២០១៦ ប្រជុំប្រចាំឆមាស នៅមន្ទីរកសិកម្មខេត្តកំពង់ធំ ដោយមានការចូលរួមពីមន្ទីរកសិកម្មខេត្តកំពង់ធំ កំពង់ចាម ត្បូងឃ្មុំ សៀមរាប និងមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមសរុបចំនួន ៣៣នាក់ ស្រីចំនួន ០៤នាក់

**២.២-គម្រោងលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀង (GIZ)**

- ថ្ងៃទី១៦ ខែកុម្ភៈ ដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ចូលរួមអង្កេតទិន្នន័យអសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ចំនួន ៨១៣គ្រួសារ នៅខេត្តកំពង់ធំ ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ
- ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ចូលរួមពិភាក្សាជាមួយទីប្រឹក្សាបច្ចេកទេសគម្រោងសន្តិសុខស្បៀង និងអាហារូត្ថម្ភ អ្នកចូលរួមសរុបចំនួន ០៨នាក់ ស្រីចំនួន ០១នាក់ នៅមន្ទីរកសិកម្មខេត្តកំពង់ធំ
- ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៦ ចុះកំណត់ទីតាំងប្រើប្រាស់ដី, ជីកអណ្តូងដៃ និងធ្វើរបងព័ទ្ធជុំវិញនៅមណ្ឌលពិសោធន៍កសិកម្ម ភូមិអូរធំ ឃុំទីពោ ស្រុកសន្ទុក អ្នកចូលរួមសរុបចំនួន ១២នាក់ ស្រីចំនួន ០៤នាក់
- ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ប្រជុំពិភាក្សាជាមួយកសិករអំពី ការជីកអណ្តូងដៃ និងធ្វើរបងព័ទ្ធជុំវិញ និងប្រគល់បញ្ជីឈ្មោះកសិកររងគ្រោះ និងកសិករងាយរងគ្រោះ ជូនប្រធានសហគមន៍ភូមិអូរធំ ឃុំទីពោ ស្រុកសន្ទុក អ្នកចូលរួមសរុបចំនួន ០៣នាក់ ស្រីចំនួន ០០នាក់ ។

## ៣-ការងារបង្កបង្កើនផល

### ៣.១-ការងារបង្កបង្កើនផលស្រូវរដូវស្រូវ ឆ្នាំ២០១៦

គិតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ អនុវត្តការងារភ្ជួររាស់ដីសរុបបានចំនួន **១៨៧.៨៨២**ហ.ត ក្នុងនោះភ្ជួរដោយត្រាក់ទ័រចំនួន **១៧៤.៣៤៩ហ.ត** ភ្ជួរដោយគោ ក្របី **១៣.៥៣៣ហ.ត** ។ ការងារបង្កបង្កើនផលស្រូវអនុវត្តបានចំនួន **១៨០.១១៨ហ.ត** ស្មើនឹង **៨៤,៤៤ភាគរយ** នៃផ្ទៃដីផែនការ ២១៣.៣០០ បើធៀបនឹងឆ្នាំមុនរយៈពេលដូចគ្នាខ្ពស់ជាងចំនួន **២៨.១៦២ហ.ត** ក្នុងនោះស្រូវវារចំនួន **១០.៥២០ហ.ត** អនុវត្តស្រូវធ្ងន់ចំនួន **៦៣.៥៨៧ហ.ត** (ស្ទូងបានចំនួន ២.៤៩៤ហ.ត) អនុវត្តស្រូវកណ្តាលបានចំនួន **៧៩.៣៥១ហ.ត** (ស្ទូងបានចំនួន ១.៩៣៩ហ.ត) អនុវត្តស្រូវស្រាលចំនួន **២៤.៤៩៤ហ.ត** (ស្ទូងបានចំនួន ៨០១ហ.ត) និងអនុវត្តស្រូវចំការបានចំនួន **២.១៦៦ហ.ត** ។

### ៣.២-ការងារដំណាំរួមផ្សំរដូវវស្សាឆ្នាំ២០១៦

គិតត្រឹមថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ ដំណាំរួមផ្សំរដូវវស្សាអនុវត្តបានចំនួន **៥៧.៤១៩**ហ.ត ក្នុងនោះដាំពោតបាន **៤២៩ហ.ត** សណ្តែកបាយ ២.៧៦១ហ.ត ឪឡឹក ៨៩៤ហ.ត បន្លែ ៣៦១ហ.ត ដំឡូងជ្វា ៩ហ.ត ដំឡូងមី ៥២.៧២៣ហ.ត និងដំណាំឧស្សាហកម្មរយៈពេលខ្លីដូចជា សណ្តែកដី ១០០ហ.ត អំពៅ ៣៥ហ.ត ល្ង ៧៧ហ.ត ។

## ៤-ការិយាល័យក្សេត្រសាស្ត្រ និងផលិតភាពកសិកម្ម

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យនេះមានមន្ត្រីសរុបចំនួន ១០នាក់ ក្នុងនោះស្រី ចំនួន ០៥នាក់ ។

### ៤.១-សកម្មភាពការងារ

- ចូលរួមប្រចាំខែនៅមន្ទីរកសិកម្មខេត្តកំពង់ធំ
- ចុះតាមដានការដាំដុះស្រូវរដូវវស្សារបស់កសិករនៅស្រុកកំពង់ស្វាយ ស្រុកបារាយណ៍ និង ក្រុងស្ទឹងសែន
- ចុះអន្តរាគមន៍កំចាត់ដង្កូវ ដោយណែនាំកសិករពីវិធីកំចាត់ដង្កូវលើដំណាំស្រូវ និងដំណាំសណ្តែក បាយនៅស្រុកប្រាសាទសំបូរ និងស្រុកសណ្តាន់
- សហការណ៍ជាមួយ IRRI ចែកពូជស្រូវសុទ្ធជូនកសិករបានចំនួន ១.១១៦គ្រួសារលើ ៤៥ ភូមិ ១១ឃុំ ០៦ស្រុក
- ចែកពូជដំណាំបន្លែជូនកសិករបានចំនួន ៧០គ្រួសារ

### ៤.២-ការងារស្ថានីយ៍ពិសោធន៍ដំណាំស្រូវបល្ល័ង្ក

- លក់ស្រូវពូជជូនកសិករបានចំនួន ៤១តោន
- ភ្ជួរត្រឡប់ដីស្រែបានចំនួន ៤ហ.ត
- ស្ទូងស្រែផលិតពូជស្រូវសែនពិដោរបានចំនួន ៣ហ.ត

## ៥-ការិយាល័យផលិតកម្ម និងបសុពេទ្យ

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យនេះមានមន្ត្រីរាជការចំនួន ១២នាក់ ស្រីចំនួន ០១ នាក់ ក្នុងនោះមន្ត្រីជាប់កិច្ចសន្យាចំនួន ០២នាក់ ស្រីចំនួន ០១នាក់ ។ ការិយាល័យនេះដឹកនាំដោយ ប្រធានការិយាល័យ ០១រូប អមដោយអនុប្រធានចំនួន ០២រូប ។

ក្នុងរយៈពេល នៃការអនុវត្តយើងបានសង្កេតឃើញថា ទូទាំងខេត្តកំពង់ធំមិនទាន់មានបាតុ ភាពកើតជំងឺផ្តាសាយបក្សីនៅឡើយទេ ។ ប៉ុន្តែមានកើតជំងឺមួយចំនួនដូចជាៈ ជំងឺអុតក្តាម និងជំងឺ សារទឹកគោ ក្របីដោយមានការខិតខំអស់ពីកម្លាំងកាយចិត្ត របស់មន្ត្រីជំនាញគ្រប់លំដាប់ថ្នាក់នឹង មានការជួយគាំទ្រពីអង្គការជាតិ និងអន្តរជាតិ ដើម្បីមានវិធានការទប់ស្កាត់ការរីករាលដាលនូវជំងឺ ទាំងនេះជូនប្រជាពលរដ្ឋបានមួយចំនួនធំ ។ ដើម្បីរួមចំណែកក្នុងការងារសន្តិសុខស្បៀងកាត់បន្ថយ ភាពក្រីក្របានសម្រេចការងារដូចជាៈ

- ការចិញ្ចឹមសត្វ
- ការកាត់បន្ថយអត្រាសត្វឈឺ
- ការទប់ស្កាត់ជំងឺគ្រុនផ្តាសាយបក្សី
- ការការពារសុខភាពសាធារណៈ
- ប្រមូលចំណូលមិនមែនសារពើពន្ធ
- ការកែច្នៃផលិតផលដែលមានដើមកំណើតពីសត្វ
- ការងារផ្សេងៗទៀតតាមការចង្អុលបង្ហាញរបស់ថ្នាក់លើ ។

### ៥.១-ការចិញ្ចឹមសត្វៈ

វិស័យចិញ្ចឹមសត្វត្រូវបានចាត់ទុកជាអាទិភាពទី២បន្ទាប់ពីដំណាំស្រូវ ដែលមានការប្រែប្រួល ឈានទៅគួរអោយកត់សំគាល់នូវការចិញ្ចឹមជាលក្ខណៈឧស្សាហកម្ម ដែលអាចធានាបាននូវកម្លាំង អូសទាញ និងសុវត្ថិភាពស្បៀងជូនប្រជាពលរដ្ឋ ។

ទោះបីជាមានការលំបាកស្មុគ្រស្មាញនៅក្នុងភារៈកិច្ចយ៉ាងណា ក៏ការិយាល័យនៅតែអាច ពុះពារ និងជំនះបានហើយបំពេញនូវតួនាទីរបស់ខ្លួនអោយទទួលបានជោគជ័យដូចជាៈ

- កាត់បន្ថយអត្រាសត្វឈឺ និងស្លាប់រាំងស្កាត់ជំងឺឆ្លងសត្វទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារ និងជាកសិដ្ឋាន
- ជំរុញការកែលំអពូជសត្វ និងចំណីសត្វនៅគ្រប់ជនបទក្នុងខេត្ត
- ពង្រឹងនិងពង្រីកសេវាកម្មសាធារណៈផ្សេងៗក្នុងវិស័យផលិតកម្ម និងបសុព្យាបាល
- លើកទឹកចិត្តដល់ការធ្វើអាជីវកម្ម និងវិនិយោគលើវិស័យចិញ្ចឹមសត្វស្របច្បាប់ការគ្រប់គ្រងរាល់កាកសំណល់សត្វ និងទំនាក់ទំនងទីផ្សារសត្វ
- លើកកម្ពស់ការវិនិយោគកែច្នៃចំណីសត្វក្នុងស្រុក
- ជំរុញការផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាលអោយកាន់តែទូលំទូលាយដល់ជនបទ ។

**៥.២-ផ្នែកផលិតកម្ម៖**

**ក-អាជីវកម្មសត្វ**

- ធ្វើអាជីវកម្មប្រមូលទិញសត្វក្នុងស្រុកសរុបមានចំនួន **១៣.៤២៩ក្បាល** ក្នុងនោះគោសរុបចំនួន ១.៣១៥ក្បាល ក្របីសរុបចំនួន ២២៩ក្បាល ជ្រូកសរុបចំនួន ៣៨៥ក្បាល និងបក្សី (មាន់/ទា)សរុបចំនួន ១១.៥០០ក្បាល
- ពិឃាតសត្វសរុបចំនួន **៤.០៦២ក្បាល** ក្នុងនោះគោសរុបចំនួន ៦០០ក្បាល ក្របីសរុបចំនួន ៨៧ក្បាល ជ្រូកសរុបចំនួន ៣.៣៧៥ក្បាល ។

**ខ-អំពីតម្លៃសត្វ សាច់ និងស៊ុត (តម្លៃគិតជាមធ្យម)**

| | | | |
|---|---|---|---|
| - គោ រស់ | តម្លៃ ២.៤៦៦.៧៨៣៛/ក្បាល | សាច់សុទ្ធ | តម្លៃ ៣២.៥៦៣៛/គ.ក្រ |
| - ក្របី រស់ | តម្លៃ ៣.១១៥.៤១៧៛/ក្បាល | សាច់សុទ្ធ | តម្លៃ ៣៣.០៦៣៛/គ.ក្រ |
| - ជ្រូក រស់ | តម្លៃ ៨.២២៨៛/គ.ក្រ | សាច់សុទ្ធ | តម្លៃ ១៦.១១៣៛/គ.ក្រ |
| - មាន់ រស់ | តម្លៃ ១៤.៩០០៛/គ.ក្រ | | |
| - ទា រស់ | តម្លៃ ១០.៨៧៥៥៛/គ.ក្រ | ស៊ុតទា | តម្លៃ ៥០៦៛/គ្រាប់ |

**៥.៣-ផ្នែកបសុព្យាបាល៖**

**ក-ការចាក់ថ្នាំ និងការព្យាបាល**

- ចុះចាក់ថ្នាំទម្លាក់ប៉ារ៉ាសិតសត្វសរុបចំនួន **៥.០៤៦ក្បាល** ក្នុងនោះគោសរុបចំនួន **២៨៨** ក្បាល ក្របីសរុបចំនួន **១៥៩**ក្បាល ជ្រូកសរុបចំនួន **៨៩៤**ក្បាល សេះសរុបចំនួន **៤**ក្បាល ឆ្កែសរុបចំនួន **៩១**ក្បាល និងមាន់សរុបចំនួន **៣.៦១០**ក្បាល
- ចុះចាក់ថ្នាំការពារជំងឺសត្វគោ ក្របី ឆ្កែសរុបចំនួន **៩.៣០២ក្បាល** ក្នុងនោះគោសរុបចំនួន **៧.៣៧១**ក្បាល និងក្របីសរុបចំនួន **១.៩៣១**ក្បាល
- ចុះចាក់ថ្នាំការពារជំងឺសត្វជ្រូក និងសត្វស្លាបសរុបចំនួន **២១.៨៩៩ក្បាល** ក្នុងនោះជ្រូកមានចំនួន **៣.១៣៧**ក្បាល និងសត្វស្លាបចំនួន **១៨.៧៦២**ក្បាល
- សត្វឈឺសរុបចំនួន **១.១១០ក្បាល** ក្នុងនោះគោសរុបចំនួន **៣៤១**ក្បាល ក្របីសរុបចំនួន **១២៧**ក្បាល ជ្រូកសរុបចំនួន **៦២២**ក្បាល និងឆ្កែសរុបចំនួន **២០**ក្បាល
- ការព្យាបាលជំងឺសត្វសរុបចំនួន **១.០១៦**ក្បាល ក្នុងនោះគោសរុបចំនួន **៣០៥**ក្បាល ក្របីសរុបចំនួន **១១៦**ក្បាល ជ្រូកសរុបចំនួន **៥៧៦**ក្បាល និងឆ្កែសរុបចំនួន **១៩**ក្បាល
- សត្វងាប់ដោយសារជំងឺសរុបចំនួន **៧៥ក្បាល** ក្នុងនោះគោសរុបចំនួន **១៣**ក្បាល ក្របីសរុបចំនួន **៩**ក្បាល ជ្រូកសរុបចំនួន **៥២**ក្បាល និងឆ្កែសរុបចំនួន **១**ក្បាល ។

**ខ-រោគសញ្ញាសត្វ**

- គោៈ ហើមពោះ រឹងជើង ទល់លាមក ហៀរទឹកមាត់ ទន់ជើង និងឡើងកំដៅ
- ក្របីៈ ហៀរទឹកមាត់ ពិបាកដកដង្ហើម ដំបៅមាត់ និងរឹងឆ្អឹងខ្នង

- ជ្រូកៈ រាកអាចម៍ រាកលឿង ប្រកាច់ មិនស៊ីចំណី និងមានពងបែកពេញខ្នង
- ឆ្កែៈ រាកឈាម ឡើងកំដៅ ហើមភ្នែក និងមិនស៊ីចំណី ។

**៥.៤-ចំណូលបង់ចូលថវិការដ្ឋៈ**

ការិយាល័យបានខិតខំប្រមូលចំណូលពីអាករ និងពិន័យបង់ចូលថវិការដ្ឋសម្រាប់ខែមិថុនានេះបានចំនួន **៩.៩០៥.៥០០រៀល** ។

**៥.៥-សកម្មភាពការងារៈ**

- ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមប្រជុំប្រចាំខែ នៅមន្ទីរកសិកម្មខេត្តកំពង់ធំ
- ថ្ងៃទី១៧-២០ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលាស្តីពី ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ របស់គម្រោង EU នៅខេត្តសៀមរាប
- ថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមសិក្ខាសាលាស្តីពី ការពិនិត្យមើលមុខងារឡើងវិញរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅរាជធានីភ្នំពេញ
- ថ្ងៃទី២៦-២៧ ខែឧសភា ឆ្នាំ២០១៦ ចុះពិនិត្យស្ថានភាពជំងឺសត្វ និងត្រួតពិនិត្យសត្តឃាតដ្ឋាន ក្នុងស្រុកកំពង់ស្វាយ
- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមប្រជុំផ្សព្វផ្សាយការបើកកសិដ្ឋានជាមួយអ្នកចិញ្ចឹមសត្វ និងណែនាំពីបច្ចេកទេសដលពួកគាត់ នៅការិយាល័យផលិតកម្ម និងបសុព្យាបាល
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ បានចូលរួមប្រជុំការងារសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅមន្ទីរកសិកម្មខេត្តកំពង់ធំ
- ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ បានចូលរួមប្រជុំប្រចាំខែមិថុនា របស់ការិយាល័យផលិតកម្ម និងបសុព្យាបាល

## ៦-ការិយាល័យគ្រឿងយន្តកសិកម្ម

**៦.១-ការងារមន្ត្រីរាជការ**

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីចំនួន ០៤នាក់ ស្រី ០០នាក់ និងដឹកនាំដោយប្រធានការិយាល័យ ០១រូប ។

**៦.២-សកម្មភាពការងារ**

**ក**-គម្រោង TSSD

- ចូលរួមសាលារៀនស្រែកសិករផលិតពូជស្រូវចំនួន ០២សាលាបានចំនួន ០៤វគ្គ កសិករសរុបចំនួន ៧៩នាក់ ស្រីចំនួន ៥៥នាក់ (ភូមិឈើទាល ស្រុកសណ្តាន់ និងភូមិសណ្តាន់ ស្រុកស្ទោង) ។

**ខ**-អង្គការកិច្ចសហប្រតិបត្តិការអាឡឺម៉ង់ (GIZ)

- បញ្ជូនមន្ត្រី ០២នាក់ចូលរួមបើកវគ្គបណ្តុះបណ្តាលដំណាំបន្លែ ដល់កសិករទទួលបានដីសម្បទានសង្គមកិច្ចបានចំនួន ០១វគ្គ កសិករសរុបចំនួន ៤២នាក់ ស្រីចំនួន ៣៣នាក់
- ចុះតាមដានការដាំបន្លែ និងឱឡឹកបានចំនួន ០៥វគ្គ កសិករ ចំនួន ០១វគ្គ កសិករសរុបចំនួន ៧៤នាក់ ស្រីចំនួន ៥៥នាក់ និងតាមដានការធ្វើទ្រុងជីកំប៉ុស្តបានចំនួន ០៥បង្ហាញ
- ដឹកនាំកសិករធ្វើទស្សនកិច្ចសិក្សា ការដាំដំណាំបន្លែ និងឈើហូបផ្លែចំនួន ០៥វគ្គ ០១ឃុំ ០២ភូមិ កសិករសរុបចំនួន ៦០នាក់ ស្រីចំនួន ២៨នាក់

**គ**-អង្គការ HOM

- ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ មន្ត្រីចំនួន ០១នាក់ចូលរួមដោះស្រាយទំនាស់ដីសហគមន៍នេសាទបឹងរៀល នៅឃុំកំពង់គោ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ
- ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ មន្ត្រីចំនួន ០១នាក់ចូលរួមជាវាគ្មិន ផ្តោតលើការប្រើប្រាស់ដី នៅឃុំស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ សមាសភាពចូលរួម សិស្សវិទ្យាល័យសរុបចំនួន ១១៣នាក់ កសិករសរុបចំនួន ៨០នាក់ ស្រីចំនួន ៦៨នាក់
- ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ បញ្ជូនមន្ត្រី ០១នាក់ចូលរួមពិភាក្សាស្តីពី ផលិតកម្មកសិកម្ម ផ្តោតលើតម្រូវការទីផ្សារ និងការលំបាករបស់មន្ទីរកសិកម្មជាមួយដៃគូ HOM /ACENHECH
- ថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ បញ្ជូនមន្ត្រី ០១នាក់ចូលរួមកម្មវិធីកាត់បន្ថយការប្រើប្រាស់សារធាតុគីមី នៅឃុំព្រៃគុយ ស្រុកកំពង់ស្វាយ អ្នកចូលរួមសរុបចំនួន ២១២នាក់ ស្រីចំនួន ៨៧នាក់ ។

**ឃ**-សកម្មភាពការងារ

- ប្រជុំប្រចាំខែមេសា របស់ការិយាល័យគ្រឿងយន្តកសិកម្ម
- ប្រជុំប្រចាំខែមេសា របស់មន្ទីរកសិកម្មខេត្តកំពង់ធំ
- ចុះស្រង់ស្ថិតិគ្រឿងយន្តកសិកម្មតាមបណ្តាស្រុក និងការងារភ្ជួររាស់ដី ។

## ៧-ការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម

### ៧.១-ការងារមន្ត្រីរាជការ

គិតត្រឹមខែមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីសរុបចំនួន ០៤នាក់ ស្រីចំនួន ០១នាក់ និងដឹកនាំដោយប្រធានការិយាល័យ ០១រូប ។

### ៧.២-ការបណ្តុះបណ្តាលកសិករ

- ថ្ងៃទី១៤-២០ ខែឧសភា ឆ្នាំ២០១៦ បង្ហាញលទ្ធផលពីការធ្វើចំណាត់ថ្នាក់ដីសម្រាប់ដំណាំស្រូវ ចំនួន ០៧លើក អ្នកចូលរួមសរុបចំនួន ៣៨៧នាក់ ស្រីចំនួន ២១០នាក់ នៅភូមិបឹងអណ្តែង តាអាំ ភ្លូង ស្រយូវត្បូង ម្នាវ រកា និងភូមិកំរែង គាំទ្រដោយ CARITAS
- ថ្ងៃទី២៨-៣០ ខែឧសភា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី គោលគំនិតក្នុងការធ្វើសវនកម្មសហគមន៍កសិកម្ម ចំនួន ០១លើក អ្នកចូលរួមសរុបចំនួន ២៤នាក់ ស្រីចំនួន ១២នាក់ នៅទីស្នាក់ការអង្គការទស្សនៈពិភពលោក គាំទ្រដោយ WVC
- ថ្ងៃទី០២-០៣ ខែមិថុនា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី បច្ចេកទេសដាំដុះដំណាំលក្ខណៈគ្រួសារ ចំនួន ០១លើក អ្នកចូលរួមសរុបចំនួន ១៥នាក់ ស្រីចំនួន ១០នាក់ នៅទីស្នាក់ការអង្គការទស្សនៈពិភពលោក គាំទ្រដោយ GIZ ។

### ៧.៣ សន្និបាត/ប្រជុំ

- ថ្ងៃទី១៧-១៨ ខែឧសភា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី ផលិតកម្មគ្រាប់ពូជស្រូវ និងបច្ចេកទេសក្រោយពេលប្រមូលផល ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ៤៣នាក់ ស្រីចំនួន ២៤នាក់ គាំទ្រដោយ IRRI
- ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី ការប្រមូលព័ត៌មាន និងប្រមូលទិន្នន័យសម្រាប់រៀបចំសេចក្តីព្រាងស្តង់ដា អង្ករផ្កាំរំដួល និងផ្កាច័ន្ទសែនសរ ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ១៧០នាក់ ស្រីចំនួន ៣៤នាក់ នៅរាជធានីភ្នំពេញ រៀបចំដោយ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- ថ្ងៃទី២៥-២៧ ខែឧសភា ឆ្នាំ២០១៦ មហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្មដូងភក្តី សិរីសាមគ្គី ចំនួន ០១លើក អ្នកចូលរួមសរុបចំនួន ៤៥២នាក់ ស្រីចំនួន ២៦៥នាក់ នៅភូមិចាន់សេរី ឃុំសាមគ្គី ស្រុកប្រាសាទបល្ល័ង្ក រៀបចំដោយ សហគមន៍
- ថ្ងៃទី២៥-២៧ ខែឧសភា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី កសិកម្មសរីរាង្គ ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ៣៧នាក់ ស្រីចំនួន ១៤នាក់ រៀបចំដោយ GIZ
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ស្តីពីសហគមន៍ ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ១២៨នាក់ ស្រីចំនួន ១៣នាក់ នៅរាជធានីភ្នំពេញ រៀបចំដោយ DGRV
- ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ចុះត្រួតពិនិត្យសម្ភារសហគមន៍កែច្នៃគ្រាប់ស្វាយចន្ទីភូមិស្វាយកាល់ ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ១៧នាក់ ស្រីចំនួន ០៤នាក់ នៅទីស្នាក់ការរបស់សហគមន៍
- ថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ២០១៦ សិក្ខាសាលាបញ្ចប់គម្រោង ការចុះបញ្ជី និងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ១៤០នាក់ ស្រីចំនួន ១៣នាក់ នៅខេត្តបាត់ដំបង
- ថ្ងៃទី០៩-១០ ខែមិថុនា ឆ្នាំ២០១៦ សិក្ខាសាលាស្តីពី ការធ្វើអាជីវកម្មសហគមន៍កសិកម្ម ចំនួន ០១វគ្គ អ្នកចូលរួមសរុបចំនួន ២៣៥នាក់ ស្រីចំនួន ៨៩នាក់ នៅរាជធានីភ្នំពេញ រៀបចំដោយ WVC
- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៦ ប្រជុំប្រមូលព័ត៌មានស្តីពី ប្រឡាយទឹករបស់សហគមន៍អូរកន្ធរមានជ័យ ចំនួន ០១លើក អ្នកចូលរួមសរុបចំនួន ០៧នាក់ ស្រីចំនួន ០២នាក់ នៅរាជធានីភ្នំពេញ រៀបចំដោយ WVC ។

## ៨-ការងារនីតិកម្មកសិកម្ម

### ៨.១ មន្ត្រីរាជការ

គិតត្រឹមមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីសរុបចំនួន ០៨នាក់ ស្រីចំនួន ០៣នាក់ ក្នុងនោះមន្ត្រីជាប់កិច្ចសន្យាចំនួន ០១នាក់ ។ ការិយាល័យនេះមានប្រធានចំនួន ០១នាក់ និងអនុប្រធានចំនួន ០៣រូប ស្រីចំនួន ០១រូប ។

### ៨.២ ការងារផ្តល់សេវាសាធារណៈដល់អាជីវករលក់គ្រាប់ពូជ ជី ថ្នាំ សម្ភារកសិកម្ម ចំណីសត្វ និងថ្នាំសត្វ

- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មជីកសិកម្ម ចំនួន ០១ ច្បាប់
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មថ្នាំកសិកម្ម ចំនួន ០១ ច្បាប់
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មជី និងថ្នាំកសិកម្ម ចំនួន ០៣ ច្បាប់
- ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មចំណីសត្វ និងថ្នាំសត្វ ចំនួន ០២ ច្បាប់
- ចំណូលសរុបពីការផ្តល់សេវា ៧០០.០០០ រៀល (ប្រាំពីរយពាន់រៀលគត់)

### ៨.៣ ការងារនីតិកម្មកសិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម

- ប្រជុំប្រចាំខែការិយាល័យនីតិកម្មកសិកម្ម
- ប្រជុំផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត ផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មដល់អាជីវករ កសិករ អំពីការទុកដាក់ ការដាក់តាំងលក់ ការវេចខ្ចប់ ការដាក់ស្លាកសញ្ញា លេខបញ្ជិកា សុពលភាពលេខបញ្ជិកា សុពលភាពប្រើប្រាស់ របៀបប្រើប្រាស់ ចំនួន ០៤លើក អ្នកចូលរួមសរុបចំនួន ៤៥៥នាក់ ស្រីចំនួន ២៥៩នាក់ ក្នុងនោះ ៖
- ក្រុងស្ទឹងសែនចំនួន ០៣លើក
- ស្រុកប្រាសាទបល្ល័ង្កចំនួន ០១លើក

- ស្រុកសន្ទុកចំនួន ០១លើក
- ស្រុកកំពង់ស្វាយចំនួន ០៣លើក ។

**៨.៤ ការងារវិវាទកសិកម្ម និងស្រាវជ្រាវ**

- ចុះណែនាំដល់អាជីវករ លក់ដុំ លក់រាយសម្ភារកសិកម្ម ដែលអស់សុពលភាព ស្នើឲ្យរួសរាន់ដាក់ពាក្យបន្តអាជីវកម្ម
- ប្រជុំជាមួយអាជីវករក្រុងស្ទឹងសែន និងស្រុកបារាយណ៍ ក្នុងការបញ្ឈប់ធ្វើអាជីវកម្មលក់សម្ភារកសិកម្ម ដែលគ្មានលិខិតអនុញ្ញាត និងក្លែងក្លាយបញ្ជិកា ។

**៨.៥ ការងារបមាណីសម្ភាកសិកម្ម**

**ក-ការធ្វើអាជីវកម្មសម្ភារកសិកម្ម**

នៅទូទាំងខេត្តកំពង់ធំ មានអាជីវករលក់ដុំ និងលក់រាយសម្ភារកសិកម្មសរុបចំនួន ២៨៨ដេប៉ូ ក្នុងនោះមាន ៨២ដេប៉ូ មិនទាន់បានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីកម្ម ដែលក្រុងស្ទឹងសែនមានចំនួន ៥៧ដេប៉ូ ។

មន្ត្រីការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មខេត្តកំពង់ធំ បានចុះចែកលិខិតជូនដំណឹងស្តីពីការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្ម បានចំនួន ២៥០ច្បាប់៖

- ស្រុកប្រាសាទបល្ល័ង្គ បានចំនួន ០៣ដេប៉ូ
- ស្រុកប្រាសាទសំបូរ បានចំនួន ១៤ដេប៉ូ
- ស្រុកស្ទោង បានចំនួន ១១ដេប៉ូ
- ស្រុកសន្ទុក បានចំនួន ០៩ដេប៉ូ
- ស្រុកបារាយណ៍ បានចំនួន ០៧ដេប៉ូ
- ក្រុងស្ទឹងសែន បានចំនួន ២៣ដេប៉ូ
- ស្រុកកំពង់ស្វាយ បានចំនួន ២៣ដេប៉ូ

**ខ-ប្រភពសម្ភារកសិកម្ម**

សម្ភារកសិកម្មដែលបានដាក់តាំងលក់ នៅក្នុងខេត្តកំពង់ធំ ភាគច្រើនជារបស់ក្រុមហ៊ុនដែលនាំចូលពីប្រទេសចិន វៀតណាម និងប្រទេសថៃ តាមរយៈខេត្តមួយចំនួនដែលមានព្រំប្រទល់ជាប់គ្នានឹងប្រទេសទាំងនេះរួមមាន៖

- មកពីប្រទេសវៀតណាម តាមច្រកខេត្តកំពង់ចាម ត្បូងឃ្មុំ តាកែវ និងខេត្តកណ្តាល
- មកពីប្រទេសចិន តាមរយៈប្រទេសវៀតណាម
- មកពីប្រទេសថៃ តាមក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

**៨.៣ សកម្មភាព**

មន្ត្រីការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មខេត្តកំពង់ធំ សហការជាមួយនាយកដ្ឋាននីតិកម្មកសិកម្ម កាលពីថ្ងៃទី២៧-៣០ ខែមិថុនា ឆ្នាំ២០១៦ ចុះត្រួតពិនិត្យការធ្វើអាជីវកម្មសម្ភារកសិកម្ម ដែលហួសសុពលភាព គ្មានលេខបញ្ជិកា មិនទាន់មានលិខិតអនុញ្ញាតធ្វើអាជីវកម្ម និងមិនទាន់ឆ្លងកាត់វគ្គអប់រំសមត្ថភាពវិជ្ជាជីវៈ ចុះចែកលិខិតជូនដំណឹង ស្តីពីការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតធ្វើអាជីវកម្មលក់សម្ភារកសិកម្ម និងការបន្តអាជីវកម្មបានចំនួន ៣០ច្បាប់ គ្រប់ស្រុកក្រុង និងចុះស្រង់ស្ថិតិ៖

- ស្រុកស្ទោង មានចំនួន ០៥ដេប៉ូ
- ស្រុកសន្ទុក មានចំនួន ០៣ដេប៉ូ
- ស្រុកបារាយណ៍ មានចំនួន ១២ដេប៉ូ
- ស្រុកកំពងស្វាយ មានចំនួន ០៤ដេប៉ូ
- ក្រុងស្ទឹងសែន មានចំនួន ០៤ដេប៉ូ

មន្ត្រីការិយាល័យនីតិកម្មកសិកម្ម នៃមន្ទីរកសិកម្មខេត្តកំពង់ធំ ចុះត្រួតពិនិត្យដេប៉ូលក់ដុំ លក់រាយជីកសិកម្ម ថ្នាំកសិកម្ម ចំណីសត្វ បសុឱសថ និងគ្រាប់ពូជដំណាំ និងបានណែនាំដល់អាជីវករដូចខាងក្រោម៖

- លក់ដូរត្រូវដាក់ដោយឡែកពីសម្ភារផ្សេងៗ
- ត្រូវមានសៀវភៅកត់ត្រាប្រចាំថ្ងៃនូវការទិញចូល និងលក់ចេញ
- ត្រូវមានវិក័យបត្រទិញចូលត្រឹមត្រូវឯកសារក្រុមហ៊ុន ដែលទទួលលក់មានលិខិតអនុញ្ញាតធ្វើអាជីវកម្មលេខបញ្ជិកាថតចម្លងទុកកន្លែងលក់
- ត្រូវតាំងលិខិតអនុញ្ញាតចេញដោយមន្ទីរកសិកម្ម និងលិខិតបញ្ជាក់វគ្គអប់រំសមត្ថភាព
- ហាមទិញចូលនិងដាក់តាំងលក់សម្ភារ ដែលមិនមានសរសេរភាសាខ្មែរលើសំបកវេចខ្ចប់
- ហាមលក់ថ្នាំកសិកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទហាមឃាត់ជាដាច់ខាត។

## ៩-ការងារកសិឧស្សាហកម្ម និងវិនិយោគដីសម្បទានក្នុងខេត្ត

### ៩.១-ការងារកសិឧស្សាហកម្ម

**ក**-មន្ត្រីរាជការ

គិតត្រឹមមីនា ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីរាជការចំនួន ០៣នាក់ ស្រីចំនួន ០០នាក់ និងដឹកនាំដោយប្រធានការិយាល័យ ០១រូប ។

**ខ**-ផ្ទៃដីដំណាំកសិឧស្សាហកម្មរយៈពេលវែង

- ផ្ទៃដីដំណាំស្វាយចន្ទីមានចំនួន **២៤.៤៩៤,៥០**ហ.ត ទិន្នផលមធ្យម ៧០០ -១៥០០គ.ក្រ/ហ.ត និងតម្លៃ ៤០០០៛/គ.ក្រ
- ផ្ទៃដីដាំដំឡូងមីមានចំនួន **៥២.៧២៣ហ.ត** ទិន្នផលមធ្យម ១៥-១៧តោន/ហ.ត
- ផ្ទៃដីដំណាំម្រេចមានចំនួន **៩៦**ហ.ត ។

### ៩.២-រោងម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនសំងួតស្រូវ និងម៉ាស៊ីនកែច្នៃមើមដំឡូងមី

| ល.រ | ស្រុក | ម៉ាស៊ីនកែច្នៃមើមដំឡូងមី | ម៉ាស៊ីនសំងួតស្រូវ | ម៉ាស៊ីនកិនស្រូវ | | |
|---|---|---|---|---|---|---|
| | | | | តូច | មធ្យម | ធំ |
| ១ | បារាយណ៍ | ៣ | ៧ | ៩៣១ | ៣៨ | ២ |
| ២ | សន្ទុក | មិនទាន់ស្រង់ | ១ | ២២០ | ១ | ០ |
| ៣ | ស្ទឹងសែន | មិនទាន់ស្រង់ | ៣ | ៣៥២ | ០ | ៥ |
| ៤ | កំពង់ស្វាយ | មិនទាន់ស្រង់ | ០ | ៩០៥ | ៣៤ | ២ |
| ៥ | ស្ទោង | មិនទាន់ស្រង់ | ០ | ៣៥១ | ៦១ | ១៥ |
| ៦ | ប្រាសាទបល្ល័ង្គ | មិនទាន់ស្រង់ | ០ | ១៧៦ | ០ | ០ |
| ៧ | ប្រាសាទសំបូរ | មិនទាន់ស្រង់ | ៤ | ៧៥៤ | ៩៦ | ២២ |
| ៨ | សណ្តាន់ | មិនទាន់ស្រង់ | ០ | ៥៣០ | ០ | ០ |
| **សរុប** | | ៣ | ១៥ | ៤.២១៩ | ២៣០ | ៤៦ |
| **សរុបរួម** | | ៤.៥១៣ | | | | |

## ១០-ការិយាល័យកៅស៊ូ

### ១០.១-ការងារមន្ត្រីរាជការ

គិតត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០១៦ ការិយាល័យមានមន្ត្រីរាជការសរុបចំនួន ០៣នាក់ ស្រីចំនួន ០២នាក់ និងដឹកនាំដោយប្រធានការិយាល័យ ០១រូប ។

### ១០.២-ការងារវិនិយោគសម្បទានដីសេដ្ឋកិច្ច

បច្ចុប្បន្ននៅទូទាំងខេត្តកំពង់ធំ មានក្រុមហ៊ុនវិនិយោគសម្បទានដីសេដ្ឋកិច្ចសរុបចំនួន២៦ក្រុមហ៊ុន មានផ្ទៃដីសរុបចំនួន **១០៣.៦៦៧ ហ.ត** ក្នុងនោះ **១៦ក្រុមហ៊ុន** គ្រប់គ្រងដោយក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានផ្ទៃដីសរុបចំនួន **៦៦.៦៥៧**ហ.ត និង**១០ក្រុមហ៊ុន** ដែលផ្ទេរពីក្រសួងបរិស្ថាន មានផ្ទៃដីសរុបចំនួន **៣៧.០១០ ហ.ត** ។

| ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច | ចំនួនក្រុមហ៊ុន | ផ្ទៃដីសរុប (ហ.ត) | ផ្ទៃដីដាំដុះ (ហ.ត) | ផ្ទៃដីចៀរដីរ (ហ.ត) |
|---|---|---|---|---|
| គ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៦ | ៦៦.៦៥៧ | ៣៧.២៧៣,២១៩ | ៣.៩៨៧,៥៩ |
| ផ្ទេរពីក្រសួងបរិស្ថានមកឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០ | ៣៧.០១០ | ២៨.១២៧,៩៤ | ៦.២០០ |
| **សរុប** | **២៦** | **១០៣.៦៦៧** | **៦៥.៤០១,១៥៩** | **១០.១៨៧,៥៩** |

**១០.៣-ដំណាំកៅស៊ូគ្រួសារ**

| ស្រុក | ចំនួនគ្រួសារ | ផ្ទៃដីដាំដុះកៅស៊ូ (ហ.ត) | ផ្ទៃដីចៀរដីរ (ហ.ត) | ផ្សេងៗ |
|---|---|---|---|---|
| បារាយណ៍ | ១២៥ | ១.៣៣២,៦០ | ៤៧៨,៥០ | |
| សណ្តាន់ | ២៩០ | ២.៣៧២,២០ | ១.៩៨៣,២០ | |
| សន្ទុក | ១៧៤ | ២.០៩២,៤១ | ១៥៧ | |
| ប្រាសាទបល្ល័ង្គ | ៦២ | ៧២៧ | ៥១,៥០ | |
| ស្ទោង | ១៣ | ១៥៦ | - | កំពុងថែទាំ |
| **សរុប** | **៦៦៤** | **៦.៦៨០,២១** | **២.៦៧០,២០** | |

**១០.៤-គម្រោងចុះបញ្ជីដីរដ្ឋ**

- ក្រុមហ៊ុនចំនួន ០៦បានចុះបញ្ជីរួច និងចំនួន ១០ក្រុមហ៊ុនទៀតមិនទាន់បានចុះ កំពុងរៀបចំឯកសារស្នើសុំ

**១០.៥-គម្រោងកម្ពុជាហារវែស**

- ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៦ ផ្តល់ជំនួយបច្ចេកទេសដល់កសិករ អំពីការពិនិត្យសំណើមដីសំអាតស្មៅ និងពូនគល់ដំណាំពោត ការបាញ់ថ្នាំសម្លាប់ដង្កូវលើដំណាំពោត
- ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦ ផ្តល់ជំនួយបច្ចេកទេសដល់កសិករ អំពីការបណ្តុះកូនដំណាំថ្មី និងសំអាតស្មៅចន្លោះរង ។

**១០.៦-អង្គការ FAO**

- ថ្ងៃទី១-២ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រមូលទិន្នន័យបឋមពីប្រជាពលរដ្ឋនៅឃុំពពកស្រុកស្ទោង ចំនួន ៦០គ្រួសារ ។

**១០.៧-សកម្មភាពការងារ**

- ថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០១៦ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការបង្កាត់ ភ្ញាស់កង្កែបក្នុងអាង និងការចិញ្ចឹមកង្កែបក្នុងអាង នៅមន្ទីរកសិកម្ម អ្នកចូលរួមសរុបចំនួន ៤៦នាក់ ស្រីចំនួន ០៩នាក់ ។
- ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំប្រចាំខែមន្ទីរកសិកម្ម អ្នកចូលរួមសរុបចំនួន ៤៦នាក់ ស្រីចំនួន ០៩នាក់

- ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីបច្ចេកទេស និងសមត្ថភាពក្នុងការប្រើប្រាស់ផលិតផល និងថ្នាំកសិកម្មរបស់ក្រុមហ៊ុនកេនរ៉ូស
- ថ្ងៃទី១៧-១៨ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំបូកសរុបការងារឆ្នាំ២០១៥ និងលើកទិសដៅឆ្នាំ២០១៦ របស់អគ្គនាយកដ្ឋានកៅស៊ូ នៅរាជធានីភ្នំពេញ
- ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ ចូលរួមប្រជុំស្តីពី ការចុះប្រមូលព័ត៌មានបឋម នៃការសិក្សាពីគម្រោងបន្សាំ សម្រាប់វិស័យកសិកម្ម និងវិស័យហេដ្ឋារចនាសម្ព័ន្ធ ផ្លូវទីក្រុង និងជនបទ នៅខេត្តកំពង់ធំ
- ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងស្តីពី ការវាយតម្លៃឥទ្ធិពល នៃការប្រែប្រួលអាកាសធាតុក្នុងផ្ទៃរងទឹកភ្លៀងទន្លេសាបកម្ពុជា រៀបចំដោយគម្រោង CDRI នៅរាជធានីភ្នំពេញ ។

## III-ការលំបាក និងការងាយស្រួល

### ១-ការលំបាក និងបញ្ហាប្រឈម

- ខ្វះប្រព័ន្ធស្រោចស្រព និងខ្វះប្រភពទឹកប្រើប្រាស់
- ខ្វះថវិកាចុះផ្សព្វផ្សាយ និងបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- ខ្វះមធ្យោបាយចុះផ្សព្វផ្សាយតាមមូលដ្ឋាន
- ខ្វះកុំព្យូទ័រប្រើប្រាស់តាមបណ្តាការិយាល័យ
- ការចំណេះដឹងរបស់មន្ត្រីពាក់ព័ន្ធនឹងបច្ចេកវិទ្យាថ្មីនៅមានកម្រិត
- ទីកន្លែងធ្វើការប្រចាំថ្ងៃតូចចង្អៀត ។

### ២-ភាពងាយស្រួល

- មានប្រព័ន្ធទំនាក់ទំនងល្អ និងរហ័សទាន់ចិត្តដូចជាប្រព័ន្ធទូរស័ព្ទ និងប្រព័ន្ធអ៊ីនធើណេត (Internet)
- មានកិច្ចសហការណ៍ល្អពីគ្រប់ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរខេត្ត រហូតដល់ថ្នាក់មូលដ្ឋាន
- ទំនាក់ទំនងល្អជាមួយអង្គការជាតិ អន្តរជាតិ និងសហគមន៍នានាក្នុងខេត្ត ក្រុង ស្រុក ។

## IV-ទិសដៅអនុវត្តបន្ត

- ធ្វើការក្រើនរំលឹក ពង្រឹងសមត្ថភាពដល់មន្ត្រីរាជការក្នុងការអនុវត្តច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានគតិយុត្ត និងកិច្ចការរដ្ឋបាល
- ពង្រឹងការងារមន្ត្រីរាជការ តាមរយៈការចុះវត្តមានប្រចាំថ្ងៃ
- បណ្តុះបណ្តាលភ្នាក់ងារសុខភាពសត្វភូមិឲ្យក្លាយជាភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ
- ទំនាក់ទំនងល្អជាមួយអង្គការដៃគូអភិវឌ្ឍន៍នានា
- សហការជាមួយគម្រោង TSSD ដើម្បីបណ្តុះបណ្តាលធ្វើបង្ហាញដល់កសិករតំបន់គោលដៅ
- សហការជាមួយគម្រោង Rice-SDP ដើម្បីបណ្តុះបណ្តាលដល់កសិករតំបន់គោលដៅ
- ជំរុញកសិករតំបន់គោលដៅឲ្យសន្សំជីធម្មជាតិ និងធ្វើកំប៉ុស្ត
- ស្រង់ស្ថិតិម៉ាស៊ីនកិនស្រូវ និងរោងចក្រកែច្នៃកសិផលតាមបណ្តាស្រុក ក្រុង
- ចុះតាមដានជំងឺសត្វតាមបណ្តាស្រុក ក្រុង
- ចុះចាក់ថ្នាំការពារ និងព្យាបាលជំងឺសត្វជូនដល់កសិករតាមបណ្តាស្រុក ក្រុង
- ត្រៀមឧបករណ៍ សម្ភារៈសម្រាប់អន្តរាគមន៍លើផ្នែកដាំដុះ និងចិញ្ចឹមសត្វ
- ជំរុញការដាំដុះដំណាំរួមផ្សំ
- ចុះផ្សព្វផ្សាយវិធានការការពារ និងទប់ស្កាត់ជំងឺផ្សេងៗ
- រៀបចំគោលនយោបាយផែនការ និងគម្រោងអភិវឌ្ឍន៍តាមវិធីសាស្ត្រ IPM (Integrated

Pest Management) ។

V-**សំណូមពរ**

- ស្នើសុំក្រសួង  បន្តផ្តល់ឱកាសដល់មន្ត្រីបច្ចេកទេសថ្នាក់ក្រោមជាតិ  បានចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលានានាទាំងក្នុងប្រទេស និងក្រៅប្រទេសបន្ថែមទៀត
- ស្នើសុំក្រសួងបន្តផ្តល់ឱកាសដល់មន្ត្រីបច្ចេកទេសថ្នាក់ក្រោមជាតិ  ដែលមានសមត្ថភាពបានទៅបន្តការសិក្សានៅក្រៅប្រទេសតាមរយៈការប្រឡងប្រជែង ។

កំពង់ធំ, ថ្ងៃទី.........ខែ..............ឆ្នាំ២០១

**បានឃើញ និងឯកភាព**

**ប្រធានមន្ទីរកសិកម្មខេត្តកំពង់ធំ**

អ្នកធ្វើរបាយការណ៍